**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ ១៣៦ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់ឧទ្យានជាតិព្រះមុនីវង្ស«បូកគោ»

## និងឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ«គីរីរម្យ»

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នសរកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី តំបន់ការពារធម្មជាតិ

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ

-បានឃើញអនុក្រឹត្យលេខ ៥៧អនក្រ/បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

**មាត្រា១.-**

ត្រូវបានកែសម្រួល និងកំណត់ផ្ទៃដីឧទ្យានជាតិព្រះមុនីវង្ស «បូកគោ» ទំហំ១៥៨.៤៥៨(មួយរយហាសិបបួនពាន់ បួនរយហាសិបប្រាំបី)ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកំពត ខេត្តព្រះសីហនុ និងខេត្តកំពង់ស្ពឺ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១ កំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកាដូចខាងក្រោម៖

| Nº | X | Y | Nº | X | Y | Nº | X | Y |
|---|---|---|---|---|---|---|---|---|
| A | 40280 | 1168653 | J | 383146 | 1220836 | S | 406537 | 1231627 |
| B | 40060 | 1168148 | K | 390001 | 1228888 | T | 408004 | 1225468 |
| C | 39514 | 1171052 | L | 390000 | 1231510 | U | 408004 | 1215883 |
| D | 38726 | 1171587 | M | 392423 | 1231605 | V | 403996 | 1210001 |
| E | 38445 | 1174392 | N | 394181 | 1227998 | W | 404999 | 1197997 |
| F | 37[illegible]487 | 1187086 | O | 396796 | 1232460 | X | 408869 | 1180152 |
| G | 377158 | 1195536 | P | 395566 | 1236924 | Y | 404933 | 1173146 |
| H | 379176 | 1205847 | Q | 402616 | 1238796 | Z | 405501 | 1170055 |
| I | 384777 | 1209233 | R | 404316 | 1232325 | | | |

**មាត្រា២.-**

ត្រូវបានកែសម្រួល និងកំណត់ផ្ទៃដីឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ«គីរីរម្យ»ទំហំ៣៥.២៣២(សាមសិបប្រាំពាន់ ពីររយសាមសិបពីរ)ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ២ កំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកាដូចខាងក្រោម៖

| Nº | X | Y | Nº | X | Y |
|---|---|---|---|---|---|
| A | 402619 | 1238913 | G | 396523 | 1261014 |
| B | 395542 | 1237006 | H | 402131 | 1260618 |
| C | 393585 | 1238477 | I | 405891 | 1257039 |
| D | 388012 | 1245801 | J | 405620 | 1249874 |
| E | 390237 | 1260167 | K | 404103 | 1244483 |
| F | 392695 | 1261817 | | | |

**មាត្រា៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ខេត្តកំពត និងខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ